ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភីកីឡាករនគរបាលជាតិកម្ពុជាក្នុងការចូលរួមប្រកួតប្រជែងមុខជំនាញ ការប្រកួតកីឡានគរបាលជាលក្ខណៈជាតិ និងអន្តរជាតិ និងប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក គ្រូបង្វឹកជំនួយ និងអ្នកដឹកនាំក្រុម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១**.-

អនុក្រឹត្យនេះមានគោលដៅកំណត់ផ្តល់ប្រាក់រង្វាន់ ចំពោះជ័យលាភី និងប្រាក់ឧបត្ថម្ភដល់គ្រូបង្វឹក គ្រូបង្វឹកជំនួយ និងអ្នកដឹកនាំក្រុម ដើម្បីជាការលើកទឹកចិត្តក្នុងការចូលរួមប្រកួតកីឡានគរបាលជាលក្ខណៈជាតិនិងអន្តរជាតិ។

**មាត្រា២**.-

ការផ្តល់ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភត្រូវអនុវត្តចំពោះកីឡាករ កីឡាការិនី ជានគរបាលជាតិកម្ពុជា ដែលត្រូវបានអនុញ្ញាតឱ្យចូលរួមប្រកួតកីឡានគរបាលជាលក្ខណៈជាតិនិងអន្តរជាតិ ទោះការប្រកួតនោះប្រព្រឹត្តទៅនៅក្នុងប្រទេស ឬនៅក្រៅប្រទេស។

**មាត្រា៣**.-

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- **ការប្រកួតកីឡានគរបាលជាលក្ខណៈជាតិ** សំដៅដល់ការប្រកួតកីឡានគរបាលដែលមកពីអង្គភាពនានានៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីជ្រើសរើសយកជ័យលាភីក្នុងកងកម្លាំងនគរបាលជាតិ។
- **ការប្រកួតកីឡានគរបាលជាលក្ខណៈអន្តរជាតិ** សំដៅដល់ការប្រកួត បឹកម្រិត គឺការប្រកួតកីឡានគរបាលអាស៊ាន ការប្រកួតកីឡានគរបាលអាស៊ី និងការប្រកួតកីឡានគរបាលពិភពលោក។
- **ជ័យលាភី** សំដៅដល់កីឡាករឬកីឡាការិនីជាឯកត្តជនឬជាក្រុម ដែលទទួលបានមេដាយក្នុងការប្រកួតជាលក្ខណៈជាតិនិងអន្តរជាតិ ទោះការប្រកួតនោះធ្វើនៅក្នុងប្រទេសឬនៅក្រៅប្រទេសក្តី។
- **គ្រូបង្វឹក** សំដៅដល់អ្នកមានជំនាញជាបុរស ឬនារី ដែលត្រូវបានចាត់តាំងឱ្យបង្វឹកលើមុខជំនាញរបស់ខ្លួនសម្រាប់ការចូលរួមប្រកួតប្រជែង។
- **គ្រូបង្វឹកជំនួយ** សំដៅដល់អ្នកជំនួយការគ្រូបង្វឹក ដែលត្រូវបានចាត់តាំងឱ្យជួយបង្វឹកត្រៀមលើមុខជំនាញរបស់ខ្លួនសម្រាប់ការចូលរួមប្រកួតប្រជែង។
- **អ្នកដឹកនាំក្រុម** សំដៅដល់អ្នកដែលទទួលបានការចាត់តាំងជាផ្លូវការ ក្នុងការដឹកនាំក្រុមកីឡា ទៅចូលរួមប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ។
- **ការប្រកួតប្រជែងជំនាញជាលក្ខណៈអន្តរជាតិ** សំដៅដល់ការប្រកួតប្រជែងបង្ហាញសមត្ថភាពលើវិញ្ញាសាជំនាញនានា ជាលក្ខណៈអន្តរជាតិ ដែលប្រព្រឹត្តទៅនៅក្នុងប្រទេស ឬនៅក្រៅប្រទេស។ ការប្រកួតប្រជែងនេះអាចជាលក្ខណៈឯកត្តបុគ្គល ឬជាក្រុមដែលកំណត់ដោយគណៈកម្មការរៀបចំការប្រកួត។

## ជំពូកទី២

## ការផ្តល់ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភ

**មាត្រា៤.-**

ប្រាក់រង្វាន់ដល់ជ័យលាភីឯកត្តជនដែលដណ្តើមបាន **មេដាយមាស មេដាយប្រាក់ និងមេដាយសំរិទ្ធ** ត្រូវបានផ្តល់ជូនដូចខាងក្រោម៖

| ល.រ | កម្រិត | ប្រភេទមេដាយ | | |
|---|---|---|---|---|
| | | មេដាយមាស | មេដាយប្រាក់ | មេដាយសំរិទ្ធ |
| ១ | កម្រិត ជាតិ | ៦ ០០០ ០០០រៀល | ៤ ០០០ ០០០រៀល | ២ ០០០ ០០០រៀល |
| ២ | កម្រិត អាស៊ាន | ២០ ០០០ ០០០រៀល | ១៥ ០០០ ០០០រៀល | ១០ ០០០ ០០០រៀល |
| ៣ | កម្រិត អាស៊ី | ៣០ ០០០ ០០០រៀល | ២០ ០០០ ០០០រៀល | ១៦ ០០០ ០០០រៀល |
| ៤ | កម្រិត ពិភពលោក | ៤០ ០០០ ០០០រៀល | ៣០ ០០០ ០០០រៀល | ២០ ០០០ ០០០រៀល |

**មាត្រា៥.-**

ចំពោះការប្រកួតដែលមានកីឡាករ ឬកីឡាការិនីជាក្រុម ហើយទទួលបានមេដាយរង្វាន់ជ័យលាភីជាក្រុមត្រូវបានផ្តល់ឱ្យដោយយកប្រាក់រង្វាន់សម្រាប់ជ័យលាភីម្នាក់ៗក្នុង **មាត្រា៤ នៃអនុក្រឹត្យនេះ** គុណនឹងចំនួនកីឡាករ ឬកីឡាការិនី ដែលបានចូលរួមប្រកួតតាមនិយាមកំណត់។

**មាត្រា៦.-**

**គ្រូបង្វឹក** ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភ ១០០% នៃប្រាក់រង្វាន់របស់ជ័យលាភីដែលទទួលបានចំណាត់ថ្នាក់មេដាយខ្ពស់ជាងគេ ក្នុងវិញ្ញាសាប្រកួតក្នុងក្រុមដែលខ្លួនទទួលបន្ទុកបង្វឹក។

**គ្រូបង្វឹកជំនួយ** ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន ៧០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក។

**អ្នកដឹកនាំក្រុម** ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន ៥០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក។

**មាត្រា៧.-**

ការផ្តល់ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភដូចមានកំណត់នៅក្នុងអនុក្រឹត្យនេះជាបន្ទុករបស់ក្រសួងមហាផ្ទៃ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ